# គម្រោងអាជីវកម្ម
# ដំណាំឈូកយកគ្រាប់






រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.)**

ខែតុលា ឆ្នាំ២០២៥

## មាតិកា


**១-សេចក្តីផ្តើម** ... ១

**២-ការអនុវត្តការដាំដុះ** ... ១

ក- ការជ្រើសទីតាំង ប្រភេទដី និងរៀបចំដី ... ១

ខ- ការជ្រើសរើសពូជ ... ២

គ- ពេលវេលាដាំដុះ ... ២

ឃ-ការដាំដុះ ... ២

ឃ.១-ការដាំដោយមើម ... ២

ឃ.២-ការដាំដោយគ្រាប់ ... ២

ឃ.៣-ការដាំដោយកូន ... ២

**៣-ការថែទាំ** ... ៣

ក-លក្ខណៈជីវសាស្ត្រដំណាំឈូក ... ៣

ក.១-វដ្តជីវិតដំណាំឈូក (Lotus Life Cycle) ... ៣

ក.២-ឫសឈូក(Rhizome) ... ៣

ក.៣-ស្លឹក (Leaves) ... ៣

ក.៤-ផ្កាឈូក (Flowers) និងផ្លែ ... ៣

ខ-ការរក្សាជម្រៅទឹក ... ៤

គ-ការដាក់ជីជាតិ ... ៤

ឃ-ការគ្រប់គ្រងស្មៅ ... ៤

ឃ.១-ស្រងែ ... ៤

ឃ.២-ស្លែទឹក ... ៥

ង-ការគ្រប់គ្រងសត្វល្អិត ... ៦

ង.១-អាហ៊ីដ ... ៦

ង.២-ទ្រីប ... ៦

ង.៣-ដង្កូវស៊ីស្លឹក ... ៦

ង.៤-ដង្កូវស៊ីរូងដើម ... ៧

ច-ការគ្រប់គ្រងជំងឺ ... ៧

ច.១- ជំងឺរលួយឫស/ មើម ..... ៧
ច.២- ជំងឺអុចស្លឹក ..... ៨
**៤-ការប្រមូលផល** ..... ៩
ក- វិធីសាស្រ្តប្រមូលផល លក្ខណៈគ្រាប់ទុំ និងការវាយជម្រុះគ្រាប់ ..... ៩
ខ- ការសម្ងួត និងរក្សាគ្រាប់ទុំ ..... ៩
**៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំណាំឈូក** ..... ១០
ក. តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំឈូកនៅខេត្តព្រៃវែង ..... ១០
❖ តារាងសង្ខេបពីចំណេញ/ ខាតរយៈពេល៣ឆ្នាំ ..... ១២
❖ និន្នាការតម្លៃធៀបនឹងថ្លៃចំណាយទាំង៣ឆ្នាំ ..... ១២
❖ ថ្លៃដើមផលិតកម្ម/១គីឡូក្រាមទាំង៣ឆ្នាំ ..... ១៣
ខ. តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំឈូកនៅខេត្តកណ្តាល ..... ១៣
❖ តារាងសង្ខេបពីចំណេញ/ ខាតរយៈពេល៣ឆ្នាំ ..... ១៥
❖ និន្នាការតម្លៃធៀបនឹងថ្លៃចំណាយទាំង៣ឆ្នាំ ..... ១៥
❖ ថ្លៃដើមផលិតកម្ម/១គីឡូក្រាមទាំង៣ឆ្នាំ ..... ១៦
**៦-បញ្ហាប្រឈម និងដំណោះស្រាយ** ..... ១៦
**៧-សេចក្តីសន្និដ្ឋាន** ..... ១៩
**៨-ប្រភពឯកសារ** ..... ១៩

# ដំណាំឈូកយកគ្រាប់

## ១-សេចក្ដីផ្ដើម

ឈូក (Sacred Lotus - Nelumbo nucifera) គឺជាប្រភេទរុក្ខជាតិដុះក្នុងទឹកដែលមានអាយុច្រើនឆ្នាំ (Herbaceous perennial aquatic plant)ដែលអាចដុះលូតលាស់ល្អនៅទីទំនាបលិចទឹកដែលមានជម្រៅទឹកជាមធ្យម ០.២ ទៅ១ម៉ែត្រ និងត្រូវការសីតុណ្ហភាពចន្លោះចាប់ពី ១៣-៣៣ºC។ សម្រាប់លក្ខខណ្ឌអាកាសធាតុនៅប្រទេសកម្ពុជា ដំណាំឈូកអាចដុះលូតលាស់ល្អ ងាយស្រួលក្នុងការថែទាំ មានទីផ្សារល្អទាំងនៅក្នុង និងក្រៅស្រុក។ ការដាំដុះដំណាំឈូកនេះអាចទាញចំណូលត្រឡប់មកវិញលឿនចាប់ពីអាយុ៤-៦ខែ រហូតដល់៣ឆ្នាំ ឬលើស បើមានការថែទាំដិតដល់ និងមានបច្ចេកទេសត្រឹមត្រូវ។

ដោយសង្កេតឃើញការដាំដុះដំណាំឈូកយកគ្រាប់របស់កសិករកាន់តែមានការកើនឡើងដោយសារតែលក្ខខណ្ឌអាកាសធាតុ ស្ថានភាពដី-ទឹកអំណោយផល មានទីផ្សារទូលាយ និងដើម្បីចូលរួមជួយដល់កសិករក្នុងការបង្កើនសមត្ថភាពបច្ចេកទេស ដោះស្រាយបញ្ហាប្រឈមដែលតែងកើតមានក្នុងដំណើរនៃការដាំដុះ កាត់បន្ថយការចំណាយថ្លៃដើម ក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានរៀបចំ "**គម្រោងអាជីវកម្មដំណាំឈូក**" ដោយបានចុះសិក្សាស្វែងយល់ពីបទពិសោធន៍ជាក់ស្ដែងពីកសិករដែលដាំដុះដំណាំឈូកផ្ទាល់នៅខេត្តកណ្ដាល និងខេត្តព្រៃវែង។ គម្រោងនេះក៏បានសិក្សារៀបចំនូវតារាងវិភាគសេដ្ឋកិច្ច ចំណូល-ចំណាយ និងថ្លៃដើមនៃការដាំដុះដំណាំឈូកលើផ្ទៃដីគំរូ ១ហិកតាផងដែរ។

## ២-ការអនុវត្តការដាំដុះ

ការអនុវត្តបច្ចេកទេសដាំដុះ ការថែទាំឱ្យបានត្រឹមត្រូវជាប្រចាំ នាំឱ្យកសិករទទួលបានទិន្នផលខ្ពស់ និងគ្រាប់ឈូកមានគុណភាពល្អ ដែលអាចបំពេញតម្រូវការទីផ្សារបាន និងលក់បានតម្លៃល្អ។ ផ្លែឈូកគិតចាប់ពីចេញផ្ការហូតដល់គ្រាប់ផ្លែទុំអាចប្រមូលផលបានគឺមានរយៈពេលចន្លោះចាប់ពី ៤៥ ទៅ ៦០ ថ្ងៃក្រោយពីផ្កាឈូកបានរីកពេញលេញ និងបានបង្កាត់លម្អងផ្ការួចហើយ ខណៈពេលក្រោយមកទៀតវាក៏វិវឌ្ឍន៍ទៅចាស់ និងទុំរបស់ផ្លែ។

**ក. ការជ្រើសទីតាំង ប្រភេទដី និងរៀបចំដី÷** ទីតាំងត្រូវមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់យ៉ាងហោចណាស់ ៦-៨ ម៉ោងក្នុងមួយថ្ងៃ ព្រោះដំណាំឈូកត្រូវការពន្លឺដើម្បីលូតលាស់បានល្អ។ ទីតាំងស្រែឈូកជាដីទំនាប បាតរាបស្មើ ជាដីប្រភេទល្បាយឥដ្ឋ ដីអាចរក្សាទឹកបានជាប្រចាំ និងនៅជិតប្រភពទឹក។ កសិករត្រូវភ្ជួរដីឱ្យម៉ដ្ឋយ៉ាងតិច២លើក ដើម្បីឱ្យដីធូរដោយលើកទី១ដើម្បីកម្ចាត់ស្មៅលុបរុក្ខជាតិផ្សេងៗទៅក្នុងដី និងលើកទី២ ភ្ជួរឱ្យដីផុសល្អ។ កសិករត្រូវយកដីទៅវិភាគរកសារធាតុចិញ្ចឹម និងវាស់ pH ដីឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ប្រភេទជី និងកម្រិតជីឱ្យបានស្របតាមតម្រូវការចាំបាច់នៃដំណាំឈូក។ កម្រិត pH ដីដែលសមស្របសម្រាប់ដំណាំឈូកលូតលាស់ល្អគឺនៅចន្លោះ ៦-៧។

**ខ-ការជ្រើសរើសពូជ ÷** ពូជឈូកយកគ្រាប់ គឺជាពូជឈូកមួយប្រភេទដែលមានដើមខ្ពស់ ស្លឹកធំ ផ្កាធំ និងគ្រាប់ធំ។ ឈូកយកគ្រាប់ដែលកសិករខ្មែរនិយមដាំមានឈ្មោះ **ឈូកបាយ**។ កសិករត្រូវជ្រើសរើសពូជដែលមានគ្រាប់ច្រើន ទំហំគ្រាប់ធំ ការលូតលាស់លឿន ធន់ជាមួយជំងឺ និងសត្វល្អិត ពូជដែលមានប្រភពច្បាស់លាស់ និងទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។

**គ-ពេលវេលាដាំដុះ÷** ពេលវេលាល្អបំផុតសម្រាប់ការដាំគឺនៅដើមរដូវវស្សាចន្លោះខែឧសភា-សីហា ព្រោះសីតុណ្ហភាព និងសំណើមបរិយាកាសមានលក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់។

**ឃ-ការដាំដុះ÷** កសិករអាចជម្រើសរើសការដាំដោយប្រើប្រាស់មើម គ្រាប់ទុំល្អ និងកូនឈូក។ ចន្លោះ និងគម្លាត ១ម៉ x ១.៥ម៉ កសិករអាចដាំកូនឈូកចំនួន ៦៦៦៧ ដើម/ហិកតា។

ឃ.១-ការដាំដោយមើម÷ ជ្រើសរើសមើមដែលនៅស្រស់ល្អ មានភ្នែកដំណុះ (Growth tips) យ៉ាងតិច ២-៣ ពន្លក ឬថ្នាំង។ ការដាំដោយមើមនេះ គឺត្រូវដាក់មើមផ្ដេកលើផ្ទៃដីភក់ក្រោមទឹក រួចសង្កត់ថ្មៗឱ្យជាប់នឹងភក់ ឬអាចផ្សាំក្នុងថង់ដីបណ្ដុះក៏បាន។ ផ្សាំក្នុងថង់ត្រូវការពេលរងចាំរហូតដល់កូនឈូកដុះ មានស្លឹកពេញលេញទើបអាចយកទៅដាំបាន។ ចំពោះការដាំមើមដោយផ្ទាល់ ទឹកគួរតែមានជម្រៅចន្លោះពី ៥-១០សង់ទីម៉ែត្ររហូតដល់មើមចាប់ផ្ដើមដុះស្លឹក បន្ទាប់មកអាចបន្ថែមជម្រៅទឹកបន្តិចម្ដងៗ។ ការផ្សាំក្នុងថង់មានអត្រាដំណុះខ្ពស់ជាងការដាំមើមដោយផ្ទាល់។ យ៉ាងណាក៏ដោយ វិធីទាំងពីរនេះត្រូវមានការគ្រប់គ្រងសំណើមដី និងកម្រិតជម្រៅទឹកឱ្យបានម៉ត់ចត់ ទើបទទួលបានអត្រាដំណុះខ្ពស់។

ឃ.២-ការដាំដោយគ្រាប់÷ ការដាំដោយគ្រាប់ត្រូវការពេលវេលាយូរ។ ដើម្បីឱ្យគ្រាប់ឈូកងាយដុះពន្លកលឿន កសិករត្រូវយកគ្រាប់ទៅដុសនឹងក្រដាស់ខាត់ ថ្ម ឬចិតនៅផ្នែកក្បាលគ្រាប់(ពន្លូញ)។ វិធីម្យ៉ាងទៀតគឺយកគ្រាប់ត្រាំក្នុងទឹកក្ដៅឧណ្ហៗដែលមានសីតុណ្ហភាព(២០-៣០អង្សាសេ) រយៈពេល ៣-៦ថ្ងៃ ដើម្បីគ្រាប់ងាយចេញពន្លកដោយផ្លាស់ប្ដូរទឹកជារៀងរាល់២៤ម៉ោងម្ដង។ នៅពេលគ្រាប់ចេញពន្លកហើយ កសិករអាចដាក់ផ្សាំក្នុងថង់រហូតមានស្លឹកមួយពេញលេញទើបអាចយកទៅដាំនៅស្រែឈូកបាន។

ឃ.៣-ការដាំដោយកូន÷ ត្រូវបំបែកកូនឈូកដែលមានស្លឹក១ពេញលេញពីស្រែឈូកទៅដាំក្នុងស្រែដែលបានរៀបចំដីរួច។ ការដាំដោយកូនជួយឱ្យការលូតលាស់លឿន ឆាប់បានទទួលផលជាងដាំដោយមើម និងគ្រាប់។ ការដាំដោយប្រើកូនបំបែកគឺចំណាយពេលវេលា និងធនធានតិចជាងការដាំដោយមើមនិងគ្រាប់។កសិករអាចជ្រើសរើសវិធីដាំណាមួយដែលសមស្របសម្រាប់ស្ថានភាពជាក់ស្ដែង។



ពូជកូនឈូកបំបែក និងការដាំ

## ៣-ការថែទាំ

ដើម្បីមានការថែទាំឱ្យបានត្រឹមត្រូវ កសិករត្រូវស្វែងយល់ពីវដ្តជីវិត និងលក្ខណៈជីវសាស្ត្រដំណាំឈូកជាមុនសិន។ ខាងក្រោមនេះជាការពិពណ៌នាខ្លះពីដំណាំឈូក÷

### ក.វដ្តជីវិត និងលក្ខណៈជីវសាស្ត្រដំណាំឈូក

ក.១-វដ្តជីវិតដំណាំឈូក (Lotus Life Cycle)÷ ដំណាំឈូកចែកជាដំណាក់កាលលូតលាស់ (Growing Stage) ដំណាក់កាលចេញផ្កា(Flowering Stage) និងដំណាក់កាលបង្កើតគ្រាប់(Seeding Stage)។ ក្នុងលក្ខខណ្ឌអាកាសធាតុនៅប្រទេសកម្ពុជា ដំណាំឈូកជាធម្មតាអាចចេញផ្កា-ផ្លែស្ទើរគ្រប់រដូវ ហើយផ្ការីកនៅពេលព្រឹក ហើយបិទនៅពេលល្ងាច។

ក.២-មើមឈូក (Rhizome)÷ ស្ថិតនៅក្នុងដីភក់ស្រទាប់បាត មើមមានលក្ខណៈក្រាស់ធំ សម្បុរទៅដោយជាតិម្សៅ មានប្រហោងខ្យល់ខាងក្នុង ផ្ទុកសារធាតុចិញ្ចឹម និងសម្រាប់បន្តពូជដោយមិនបាច់ប្រើគ្រាប់(បន្តពូជដោយលូតលាស់)។

ក.៣-ស្លឹក (Leaves)÷មានពីរប្រភេទស្លឹកអណ្តែត (Floating leaves)ដែលអណ្តែតលើផ្ទៃទឹក និងស្លឹកឈរ (Aerial/Emergent leaves) ជាស្លឹកធំៗ រាងមូលដូចឆត្រ ដែលឈរខ្ពស់ផុតពីផ្ទៃទឹក។ ស្លឹកឈូកមានផ្ទៃរលោងដូចក្រមួន និងមានលក្ខណៈពិសេសមួយហៅថា "Lotus Effect" ដែលធ្វើឱ្យទឹកមិនជាប់ និងអាចលាងសម្អាតខ្លួនឯងបាន។

ក.៤-ផ្កាឈូក (Flowers) និងផ្លែ÷មានទំហំធំ (ពី ១០ ទៅ ១៥ ស.ម) ពណ៌ស ឬផ្កាឈូក មានក្លិនក្រអូប ផុសចេញពីទងផ្កាដ៏រឹងមាំរបស់វា។ ផ្កានីមួយៗមានទាំងលំអងផ្កាឈ្មោល និងញី ហើយជាធម្មតារីកតែពីរបីថ្ងៃប៉ុណ្ណោះបន្ទាប់មករោយ បង្កើតជាផ្លែ និងគ្រាប់។ ផ្នែកនៅចំកណ្តាលផ្កាមានផ្លែរាងដូចកោណដែលជាកន្លែងផ្ទុកគ្រាប់។ នៅពេលផ្កាជ្រុះអស់ ផ្លែគ្រាប់ឈូក (Seed Pod) រាងមូលនោះនឹងប្រែពីពណ៌បៃតងទៅជាពណ៌ត្នោត ហើយងក់ចុះមកក្រោមទឹកដើម្បីទម្លាក់គ្រាប់ ក្នុងករណីមិនបានប្រមូលផលទាន់ពេល។ គ្រាប់ឈូកទុំមានសម្បកខាងក្រៅរឹងមាំខ្លាំង ដែលអនុញ្ញាតឱ្យវាអាចនៅ សម្ងំ និងរក្សាជីវិតបានរាប់រយឆ្នាំរហូតដល់លក្ខខណ្ឌអាកាសធាតុសមស្របទើបចេញដំណុះ (តាមការស្រាវជ្រាវ)។



ឫស ស្លឹក និងផ្កាឈូក

**ខ-ការរក្សាជម្រៅទឹក÷** នៅពេលកូនឈូកចាប់ផ្ដើមលូតលាស់ពេញលេញ (ស្លឹកដុះផុតពីទឹក) ត្រូវរក្សាជម្រៅទឹកប្រហែល ២០-៦០ សង់ទីម៉ែត្រ។ កសិករត្រូវរក្សាជម្រៅទឹកមិនឱ្យលើសពី១ម៉ែត្រ និងត្រូវធានាថាស្រែដាំឈូកមានទឹកគ្រប់គ្រាន់ មិនរីងស្ងួត។

**គ-ការដាក់ជីជាតិ÷** ដំណាំឈូកត្រូវការជីជាតិច្រើនដើម្បីបែកកគុម្ព បង្កើតស្លឹក ផ្កា-ផ្លែ និងការដាក់គ្រាប់ក្នុងផ្លែ។ ការបាចជីកំប៉ុសទ្រាប់បាតជួយបង្កើនគុណភាពដី កំបោរកសិកម្មជួយកែសម្រួល pH ដីនិងបង្ការជំងឺផ្សេងៗ ជីគីមីជួយជំរុញការលូតលាស់លឿន ការចេញផ្កា-ផ្លែ និងដាក់គ្រាប់បានល្អ ដូចជា អ៊ុយរ៉េ (៤៦-០-០) ដេ អា ប៉េ (១៨-៤៦-០) និងជីប៉ូតាស្យូម(កាលី÷ ០-០-៦០)។ បរិមាណជីដែលត្រូវបាចអាស្រ័យលើគុណភាពដី តាមវគ្គលូតលាស់ និងវគ្គផ្កា-ផ្លែរបស់ដំណាំឈូក។ យ៉ាងណាក៏ដោយ មុននឹងបាចជីកសិករត្រូវបង្ហូរទឹកចេញឱ្យនៅជម្រៅចន្លោះពី ១០-១៥ស.ម ព្រោះកាលណាទឹកជ្រៅពេកនឹងបន្ថយប្រសិទ្ធភាពនៃការស្រូបយកជី។ នេះជាការណែនាំការប្រើប្រាស់ជីលើដំណាំឈូកសម្រាប់ឆ្នាំទី១ និងបញ្ឈប់ការប្រើប្រាស់កំបោរកសិកម្ម និងបន្ថយជីអ៊ុយរ៉េនៅឆ្នាំទី២-៣÷

- ដាក់ជីទ្រាប់បាត÷ ជីគ្រាប់ធម្មជាតិ ១០០-២០០គ.ក/ហិកតា +កំបោរកសិកម្ម១០០គ.ក/ហិកតា មុនពេលភ្ជួរលើកទី២
- ២០ថ្ងៃក្រោយដាំ÷ ដាក់អ៊ុយរ៉េ Urea (៤៦-០-០) ៧៥ គ.ក/ ហិកតា + ៥០គ.ក/ ហិកតា DAP (១៨-៤៦-០) សម្រាប់ការលូតលាស់ ឫស ស្លឹក បែកកូន(បែកគុម្ព) និងឆាប់ចេញផ្កា-ផ្លែ
- ៦០ថ្ងៃក្រោយដាំ÷ ៥០ គ.ក DAP/ ហិកតា ដើម្បីរក្សាតុល្យភាពលូតលាស់ឫស និងជំរុញចេញផ្កា
- ៨០ថ្ងៃក្រោយដាំ÷ ៥០គ.ក ជីកាលី (០-០-៦០) + ៥០គ.ក DAP/ ហិកតា ដើម្បីពង្រឹងគុណភាពផ្កា-ផ្លែ

ការប្រើប្រាស់ជីឱ្យមានតុល្យភាពនឹងធ្វើឱ្យដំណាំឈូកលូតលាស់ល្អ ធន់នឹងសត្វល្អិតនិងជំងឺ ចេញផ្កាស្រុះល្អ និងមានគ្រាប់ពេញល្អ (មានគ្រាប់ស្ដៀតតិចនៅក្នុងផ្លែ)។ នៅពេលចំនួនផ្កា និងផ្លែថយចុះ កសិករត្រូវ បន្ថែមជីដែលមានកម្រិតសារធាតុចិញ្ចឹម ផូស្វ័រ (P) ខ្ពស់ ប៉ូតាស្យូម (K) ខ្ពស់ និងអាសូតទាប ដូចជា ដេអាប៉េ DAP (១៨-៤៦-០) លាយជាមួយជីប៉ូតាស្យូម K (0-0-៦០) ដើម្បីបង្កើតផ្កា និងគុណភាពគ្រាប់។

**ឃ-ការគ្រប់គ្រងស្មៅ÷** ប្រភេទស្មៅដែលប្រជែងនឹងដំណាំឈូកមានដូចជា÷

ឃ.១-ស្រងែ ÷ អាចដុះលឿន និងរីករាលដាលខ្លាំង ប្រសិនបើមិនបានគ្រប់គ្រងបានល្អ វានឹងប្រកួតប្រជែងជាមួយឈូក។

វិធានការ÷ កសិករអាចសម្អាតដោយបោចនឹងដៃ ឧបករណ៍កាត់ផ្សេងៗ និងប្រើប្រាស់ថ្នាំពុលគីមីកសិកម្មដោយពិភាក្សាជាមួយអ្នកជំនាញមុននឹងជ្រើសរើសថ្នាំណាមួយយកមកប្រើប្រាស់។





ប្រភេទស្រងែ និងស្មៅនៅក្នុងស្រែឈូក

ឃ.២-ស្លែទឹក (Filamentous Algae)÷ ស្លែប្រភេទនេះលូតលាស់លឿននៅពេលទឹកក្នុងស្រែរាក់ ទឹកថ្លាល្អ មានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ ដោយរីករាលដាលគ្របដណ្ដប់លើផ្ទៃទឹក និងរំខានដល់ការលូតលាស់របស់ឈូក។

វិធានការ÷ ១) ការរក្សាកម្រិតទឹកក្នុងស្រែឱ្យខ្ពស់ ដើម្បីកាត់បន្ថយពន្លឺព្រះអាទិត្យដែលចាំងដល់បាតស្រែដែលជាកន្លែងស្លែទឹកចាប់ផ្ដើមដុះ។ ២) ចិញ្ចឹមត្រីប្រភេទស៊ីស្លែដូចជាត្រីឆ្កិន ត្រីកាបស៊ីស្មៅ អាចជួយស៊ីស្លែទឹកបានយ៉ាងមានប្រសិទ្ធភាព។ ៣) យកស្លែទឹកចេញ÷ កសិករត្រូវយកវាចេញដោយដៃ ឬប្រើឧបករណ៍សមស្របជាប្រចាំ ដើម្បីកុំឱ្យស្លែរីករាលដាលខ្លាំង។





ប្រភេទស្លែដែលតែងតែដុះក្នុងស្រែនៃដំណាំឈូក

ការគ្រប់គ្រងស្មៅក្នុងដំណាំឈូកគឺមានសារៈសំខាន់ណាស់ ដើម្បីធានាបាននូវទិន្នផលខ្ពស់។ វិធីសាស្ត្រក្នុងការគ្រប់គ្រងរួមមាន÷ ការដកស្មៅដោយដៃ ការគ្រប់គ្រងកម្រិតទឹក ការប្រើថ្នាំស្មៅ និងការប្រើប្រាស់វិធីសាស្ត្រកសិកម្មល្អផ្សេងៗទៀត ដើម្បីរួមចំណែកក្នុងការបន្ថយថ្លៃផលិតដើម និងផលប៉ះពាល់ដល់បរិស្ថាន។ កសិករត្រូវគ្រប់គ្រងស្មៅ និងរុក្ខជាតិចង្រៃផ្សេងៗ មុនពេលរាលដាលពេញស្រែឈូក រហូតដល់ដំណាំឈូកបែកកូនពេញទើបឈប់ ព្រោះស្មៅទាំងនោះមិនអាចប្រជែងឈ្នះដំណាំឈូកទៀតឡើយ។

**ង-ការគ្រប់គ្រងសត្វល្អិត÷** ប្រភេទសត្វល្អិតលើដំណាំឈូកមានដូចជា អាហ៊ីដ(ចៃ) ទ្រីប(ក្រា) ខ្យងទឹក ដង្កូវកន្ទិចអារ(ស៊ីស្លឹក) និងប្រភេទដង្កូវ(ស៊ីស្លឹក ស៊ីរូងដើម និងស៊ីផ្លែ/គ្រាប់ខ្ចី)។

ង.១-អាហ៊ីដ÷ជាពពួកចៃតូចៗដែលតោងស្អិតទៅនឹងផ្ទៃស្លឹកឈូកខ្ចីផ្នែកខាងក្រោមដែលទើបលាស់ថ្មីហើយបឺតរុក្ខរសរបស់ស្លឹក ឬបឺតលើស្រទាប់ផ្កា ដែលប៉ះពាល់ផ្កា និងការលូតលាស់ដំណាំឈូក។ ការបំផ្លាញរបស់អាហ៊ីដអាចបណ្ដាលឱ្យស្លឹក និងផ្ការួញ ក្រិន ឬប្រែពណ៌។

វិធានការ÷កាត់ស្លឹក ឬផ្កា ដែលមានចៃបំផ្លាញចោល ដើម្បីបង្ការការឆ្លងទៅដើមផ្សេងៗទៀត។ ក្នុងករណីមានការបំផ្លាញច្រើនអាចប្រើថ្នាំគីមីដោមានការណែនាំពីអ្នកជំនាញ ដូចជា Imidacloprid។

ង.២-ទ្រីប÷ជាពពួកសត្វល្អិតបឺតជញ្ជក់យករុក្ខរសលើផ្ទៃខាងក្រោមនៃស្លឹកឈូកដែលអាចធ្វើឱ្យស្លឹកឈូករួញ ឬស្វិត។

វិធានការ÷ កសិករអាចប្រើថ្នាំផ្សំពីធម្មជាតិដើម្បីបណ្ដេញ ក្នុងករណីមានការបំផ្លាញតិច។ បើមានការបំផ្លាញច្រើនអាចប្រើថ្នាំគីមីដោយមានការណែនាំពីអ្នកជំនាញ ដូចជា Thiamethoxam។




ប្រភេទទ្រីបបំផ្លាញលើផ្ទៃខ្នងស្លឹកនៃដំណាំឈូក

កសិករត្រូវឧស្សាហ៍ត្រួតពិនិត្យស្លឹកឈូកជាប្រចាំ អង្កេតមើលប្រភេទមេអំបៅដែលហើរនៅក្នុងស្រែឈូកព្រោះជាមេបារបស់ដង្កូវ។ មេអំបៅនឹងទៅបញ្ចេញពងលើស្លឹកឈូកដែលលូតលាស់ខ្ចីៗ និងញាស់ជាដង្កូវដែលបំផ្លាញស្លឹកផ្ការបស់ដំណាំឈូក។

ង.៣-ដង្កូវស៊ីស្លឹក (Leafcutter Caterpillars) ÷ ដង្កូវប្រភេទនេះស៊ីជាលិកាស្លឹកផ្នែកខាងក្រោម ឬខាងលើស្លឹក ដែលអាចបំផ្លាញទ្រង់ទ្រាយធំ ប្រសិនបើកសិករមិនបានតាមដានឱ្យបានដិតដល់។

វិធានការ÷ ១)ចាប់មេអំបៅដោយកន្ត្រងស្បៃ ២)បាញ់ថ្នាំគីមីលើពង និងដង្កូវនៅផ្ទៃស្លឹកខាងលើ និងក្រោម។

ង.៤-ដង្កូវស៊ីរូងដើម (Stem Borers)÷ ដង្កូវប្រភេទនេះចោះចូលទៅបំផ្លាញជាលិកាក្នុងដើមឈូក បណ្ដាលឱ្យដើមស្លឹក/ផ្លែងាប់ឬរលួយ។ ការបំផ្លាញនេះអាចពិបាករកឃើញនៅដំណាក់កាលដំបូង ប៉ុន្តែកសិករពិនិត្យឱ្យបានដិតដល់ប្រាកដជាឃើញស្នាមចោះនៅកស្លឹក និងកផ្លែ។

វិធានការ÷ ប្រើថ្នាំប្រភេទជ្រាបទើបអាចកម្ចាត់បាន ដូចជាថ្នាំមានធាតុសកម្ម Fipronil ឆ្លាស់ Abamectin។ បើក្នុងករណីមានការបំផ្លាញតិចតួច កសិករអាចកាត់ដើមយកមកបំផ្លាញចោល។



ប្រភេទដង្កូវលើស្លឹកឈូក



ប្រភេទដង្កូវលើស្លឹក និងស៊ីរូងដើមឈូក

ច-ការគ្រប់គ្រងជំងឺ÷កាត់ស្លឹកណាដែលងាប់ ខូចខាត ឬមានរោគសញ្ញាជំងឺចេញជាប្រចាំ ដើម្បីកាត់បន្ថយការរីករាលដាល។ ជំងឺលើដំណាំមិនមានច្រើននោះទេ ហើយភាគច្រើនបណ្ដាលមកពីការគ្រប់គ្រងទឹក និងជីជាតិមិនបានល្អ ឬការឆ្លងមេរោគ÷

ច.១-ជំងឺរលួយឫស/មើម (Root Rot)÷មើមឈូកចាប់ផ្ដើមរលួយ ប្រែជាពណ៌ខ្មៅ ឬត្នោតហើយដើមឈូកចាប់ផ្ដើមលឿង រួញ ឬងាប់ បណ្ដាលមកពីអ៊ីដ្រូសែនស៊ុលហ្វីត (Hydrogen Sulfide,)ច្រើនពេកក្នុងដីភក់ ការកង្វះអុកស៊ីសែន និងផ្សិត។

វិធានការ÷១)ត្រូវរៀបចំដីមុនដាំបានល្អ ២)វាស់pH ដីនិងកែសម្រួលឱ្យនៅចន្លោះ៦-៧ ៣ប្រើថ្នាំ copper hydroxide ដើម្បីព្យាបាលជំងឺ ៤)រក្សាគុណភាពទឹកឱ្យបានល្អតាមរយៈការបញ្ចេញបញ្ចូលទឹក និងដកមើមដែលរលួយចេញ។



ជំងឺបាក់តេរី - ផ្សិត លើក្រអៅ និងមើមឈូក

ច. ២- ជំងឺអុចស្លឹក (Leaf Spot) ÷រោគសញ្ញាស្នាមអុចៗពណ៌ត្នោត ឬខ្មៅនៅលើស្លឹក ដែលអាចរីករាលដាលធំ ឬបណ្តាលឱ្យស្លឹកងាប់។ ជំងឺនេះបង្ករឡើងដោយពពួកផ្សិត ឬបាក់តេរី អាចកើតឡើងនៅពេលអាកាសធាតុមានសំណើរខ្ពស់ និងសន្សើមអាស៊ីត។

វិធានការ÷ កាត់ស្លឹកដែលឆ្លងជំងឺចេញ និងកម្ទេចចោល និងប្រើថ្នាំការពារផ្សិត (Azoxystrobin, Mancozeb) ប្រសិនបើចាំបាច់។ កសិករត្រូវបង្ហូរទឹកចេញឱ្យអស់ និងទុកដីឱ្យស្រស់ទឹក មុននឹងប្រើថ្នាំផ្សិតទើបមានប្រសិទ្ធភាព។



ជំងឺអុចលើស្លឹកឈូក

## ៤-ការប្រមូលផល

ដំណាំឈូកអាចផ្តល់ទិន្នផលគ្រាប់ស្ងួតជាមធ្យមពី ១,៥០០-២,០០០គ.ក/ហិកតា/ឆ្នាំ និងបន្តប្រមូលផលរហូតដល់អាយុ៣ឆ្នាំ ឬច្រើនជាងនេះ អាស្រ័យលើការថែទាំ។ ការប្រមូលបានត្រឹមត្រូវជួយរក្សាគុណភាពគ្រាប់ និងបន្ថយអត្រាបាត់បង់ទិន្នផលគ្រាប់ឈូក។

**ក-វិធីសាស្ត្រប្រមូលផល លក្ខណៈគ្រាប់ទុំ និងការវាយជម្រុះគ្រាប់÷** ដំណាំឈូកចាប់ផ្តើមចេញផ្កានៅខែទី២-៣ក្រោយដាំ ហើយអាចប្រមូលផលគ្រាប់ទុំបាននៅខែ៤-៥ខែ។ បើគិតចាប់ពីចេញផ្ការហូតដល់គ្រាប់ផ្លែទុំមានរយៈពេល៤៥-៦០ថ្ងៃ។ លក្ខណៈសម្គាល់នៃគ្រាប់ឈូកទុំល្អ គឺរន្ធគ្រាប់ សំបកគ្រាប់ មានពណ៌ខ្មៅ ក្បាលគ្រាប់រឹងនៅពេលសាកល្បងសង្កត់ដោយម្រាមដៃ ហើយគ្រាប់ចាប់ផ្តើមរលុងនៅក្នុងផ្លែ។ នៅពេលកសិករសង្កេតឃើញស្ថានភាពផ្លែបែបនេះ ត្រូវប្រញាប់ប្រមូលផល ព្រោះនៅពេលទុកយូរ គ្រាប់ឈូកនឹងជ្រុះចេញពីផ្លែដែលនាំឱ្យបាត់បង់ទិន្នផល។ ក្រោយប្រមូលផ្លែឈូករួច កសិករត្រូវវាយជម្រុះគ្រាប់ចេញ មិនត្រូវទុកយូរដែលនាំឱ្យខូចគុណភាពគ្រាប់។ ចំណែកសំបកផ្លែឈូក កសិករអាចយកមកធ្វើជាជីកំប៉ុសបានព្រោះមានផ្ទុកសារធាតុផូស្វ័រ(P) និង ប៉ូតាស្យូម(K)។

**ខ-ការសម្ងួត និងរក្សាទុកគ្រាប់ទុំ÷** បើចង់លក់ជាគ្រាប់ស្ងួត កសិករត្រូវសម្ងួតវាឱ្យបានត្រឹមត្រូវរហូតដល់កម្រិតសំណើមចុះមកត្រឹមចន្លោះពី ១០-១២%ដើម្បីរក្សាគុណភាពបានយូរ និងជៀសវាងការដុះផ្សិត។ ការហាលសម្ងួតដោយកម្តៅថ្ងៃ អាចចំណាយពេលពី ៣-៥ថ្ងៃ ទើបគ្រាប់ឈូកស្ងួតល្អ។



លក្ខណៈគ្រាប់ឈូកដែលអាចប្រមូលផលបាន និងការហាលសម្ងួតដោយកម្តៅថ្ងៃ

## ៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំណាំឈូក

### ក. តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំឈូកយកគ្រាប់នៅខេត្តព្រៃវែង(១ហិកតា)

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | ចំណាយសរុប (រៀល) | ចំនួនសារវិលស់ (រៀល) | ការចំណាយក្រោយរំលស់ (រៀល) |
|---|---|---|---|---|---|---|
| **I-ឆ្នាំទី១** | | | | | | |
| **I. ក. ចំណាយ** | | | | **13,953,500** | | **10,380,167** |
| ថ្លៃភ្ជួររាស់ដី | ដង | 3 | 150,000 | 450,000 | | 450,000 |
| ពូជឈូក | គុម្ព | 6,667 | 200 | 1,333,400 | | 1,333,400 |
| ឈ្នួលដាំកូនឈូក | គុម្ព | 6,667 | 300 | 2,000,100 | | 2,000,100 |
| កំបោរកសិកម្ម | គ. ក | 100 | 1,200 | 120,000 | | 120,000 |
| ជីគីមី DAP ទ្រាប់បាត | គ. ក | 100 | 2,800 | 280,000 | | 280,000 |
| ជីទ្រាប់បាត(ជីធម្មជាតិសញ្ញាផែនដី) | គ. ក | 200 | 2300 | 460,000 | | 460,000 |
| ឈ្នួលសម្អាតស្មៅ | ដង | 1 | 150,000 | 150,000 | | 150,000 |
| ថ្លៃអគ្គិសនីបូមទឹក | ខែ | 6 | 400,000 | 2,400,000 | | 2,400,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |
| ជីគីមីបំប៉ន(Urea,DAP និង Kali)=២៥០គ.ក/ហិកតា | គ. ក | 250 | 3,000 | 750,000 | | 750,000 |
| ឈ្នួលប្រមូលផលផ្លែឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ថ្លៃខួងអណ្តូង និងម៉ូទ័របូទឹក | ឈុត | 1 | 5,200,000 | 5,200,000 | 3 | 1,733,333 |
| ធុងបាញ់ថ្នាំ(ម៉ូទ័រ) | គ្រឿង | 1 | 160,000 | 160,000 | 3 | 53,333 |
| **I. ខ. ចំណូលឆ្នាំទី១** | | | | **11,175,000** | | **11,175,000** |
| ការលក់គ្រាប់ឈូក | គ. ក | 1,850 | 6,000 | 11,100,000 | | 11,100,000 |
| ផ្សេងៗ(លក់ស្លឹក) | គ. ក | 50 | 1,500 | 75,000 | | 75,000 |
| **I. គ. លទ្ធផលចំណេញ-ខាតឆ្នាំទី១= (I. ខ - I. ក)** | | | | **-2,778,500** | | **794,833** |
| **II-ឆ្នាំទី២** | | | | | | |
| **II. ក. ចំណាយ** | | | | **4,360,000** | | **6,146,667** |
| ថ្លៃរាស់ដី | ដង | 2 | 75,000 | 150,000 | | 150,000 |
| ជីបំប៉ន(ជីធម្មជាតិសញ្ញាផែនដី) | គ. ក | 200 | 2300 | 460,000 | | 460,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្លៃអគ្គិសនីបូមទឹក | ខែ | 6 | 400,000 | 2,400,000 | | 2,400,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |
| ជីគីមីបំប៉ន(Urea,DAP និង Kali)=២៥០គ.ក/ហិកតា | គ.ក | 250 | 2,800 | 700,000 | | 700,000 |
| ឈ្នួលប្រមូលផលផ្លៃឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ថ្លៃខួងអណ្តូង និងម៉ូទ័របូមទឹក | ឈុត | 1 | 5,200,000 | 5,200,000* | 3 | 1,733,333 |
| ធុងបាញ់ថ្នាំ(ម៉ូទ័រ) | គ្រឿង | 1 | 160,000 | 160,000* | 3 | 53,333 |
| **II.ខ. ចំណូល** | | | | **10,350,000** | | **10,350,000** |
| ការលក់គ្រាប់ឈូក | គ.ក | 1,700 | 6,000 | 10,200,000 | | 10,200,000 |
| ផ្សេងៗ(លក់ស្លឹក) | គ.ក | 100 | 1,500 | 150,000 | | 150,000 |
| **II.គ. លទ្ធផលចំណេញ-ខាតបង្គរឆ្នាំទី២=(II.ខ-II.ក)+I.គ** | | | | **3,211,500** | | **4,998,167** |
| III-**ឆ្នាំទី៣** | | | | | | |
| **III.ក. ចំណាយ** | | | | **4,360,000** | | **6,146,667** |
| ថ្លៃភ្ជួររាស់ដី | ឈុត | 1 | 150,000 | 150,000 | | 150,000 |
| ជីបំប៉ន(ជីធម្មជាតិសញ្ញាផែនដី) | គ.ក | 200 | 2300 | 460,000 | | 460,000 |
| ថ្លៃអគ្គិសនីបូមទឹក | ខែ | 6 | 400,000 | 2,400,000 | | 2,400,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |
| ជីគីមីបំប៉ន(Urea, DAP និង Kali)=២៥០គ.ក/ហិកតា | គ.ក | 250 | 2,800 | 700,000 | | 700,000 |
| ឈ្នួលប្រមូលផលផ្លៃឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 25,000 | 200,000 | | 200,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ថ្លៃខួងអណ្តូង និងម៉ូទ័របូមទឹក | ឈុត | 1 | 5,200,000 | 5,200,000* | 3 | 1,733,333 |
| ធុងបាញ់ថ្នាំ(ម៉ូទ័រ) | គ្រឿង | 1 | 160,000 | 160,000* | 3 | 53,333 |
| **III.ខ. ចំណូល** | | | | **10,425,000** | | **10,425,000** |
| ការលក់គ្រាប់ឈូកឆ្នាំទី៣ | គ.ក | 1,700 | 6,000 | 10,200,000 | | 10,200,000 |
| ផ្សេងៗ(លក់ស្លឹក) | គ.ក | 150 | 1,500 | 225,000 | | 225,000 |
| **III.គ. លទ្ធផលចំណេញ-ខាតបង្គរត្រឹមឆ្នាំទី៣ = (III.ខ-III.ក)+II.គ** | | | | **9,276,500** | | **9,276,500** |

**សម្គាល់÷** លេខមានសញ្ញាផ្កាយមិនត្រូវបានបូកបញ្ចូលក្នុងការចំណាយឡើយ (ឆ្នាំទី២ និងទី៣)។

❖ តារាងសង្ខេបពីចំណេញ/ខាតរយៈពេល៣ឆ្នាំនៅខេត្តព្រៃវែង

| ឆ្នាំ | ទិន្នផលគ្រាប់ឈូកស្ងួត (គ.ក/ហ.ត) | តម្លៃ (រៀល) | ចំណូលសរុប(រៀល) | ចំណាយសរុប (រៀល) | លទ្ធផលបង្ករ ចំណេញ-ខាត (រៀល) |
|---|---|---|---|---|---|
| ទី១ | 1,850 | 6,000 | 11,100,000 | 13,953,500 | -2,778,500 |
| | 50 | 1,500 | 75,000 | | |
| ទី២ | 1,700 | 6,000 | 10,200,000 | 4,360,000 | 3,211,500 |
| | 100 | 1,500 | 150,000 | | |
| ទី៣ | 1,700 | 6,000 | 10,200,000 | 4,660,000 | 9,276,500 |
| | 150 | 1,500 | 225,000 | | |

❖ និន្នាការតម្លៃធៀបនឹងថ្លៃចំណាយទាំង៣ឆ្នាំនៅខេត្តព្រៃវែង

| ទិន្នផលគ្រាប់ស្ងួត/ហ.ត (គ.ក) | និន្នាការតម្លៃ (រៀល/គ. ក) | តម្លៃសរុប (រៀល) | ចំណាយដុលតាមឆ្នាំ (រៀល) | ចំណេញ/ខាតតាមឆ្នាំ (រៀល) |
|---|---|---|---|---|
| **I-ទិន្នផល និន្នាការតម្លៃធៀបនឹងការចំណាយដុលនិងរំលស់ឆ្នាំទី១** | | | | |
| 1,700 | 5,000 | 8,500,000 | 13,953,500 | -5,453,500 |
| 1,700 | 6,000 | 10,200,000 | 13,953,500 | -3,753,500 |
| 1,700 | 7,000 | 11,900,000 | 13,953,500 | -2,053,500 |
| 1,700 | 8,000 | 13,600,000 | 13,953,500 | -353,500 |
| 1,700 | 9,000 | 15,300,000 | 13,953,500 | 1,346,500 |
| 1,700 | 10,000 | 17,000,000 | 13,953,500 | 3,046,500 |
| **II-ទិន្នផល និន្នាការតម្លៃធៀបនឹងការចំណាយឆ្នាំទី២** | | | | |
| 1,700 | 4,000 | 6,800,000 | 4,360,000 | 2,440,000 |
| 1,700 | 6,000 | 10,200,000 | 4,360,000 | 5,840,000 |
| 1,700 | 7,000 | 11,900,000 | 4,360,000 | 7,540,000 |
| 1,700 | 8,000 | 13,600,000 | 4,360,000 | 9,240,000 |
| 1,700 | 9,000 | 15,300,000 | 4,360,000 | 10,940,000 |
| 1,700 | 10,000 | 17,000,000 | 4,360,000 | 12,640,000 |
| **III-ទិន្នផល និន្នាការតម្លៃធៀបនឹងការចំណាយឆ្នាំទី៣** | | | | |
| 1,700 | 4,000 | 6,800,000 | 4,360,000 | 2,440,000 |
| 1,700 | 5,000 | 8,500,000 | 4,360,000 | 4,140,000 |
| 1,700 | 6,000 | 10,200,000 | 4,360,000 | 5,840,000 |
| 1,700 | 7,000 | 11,900,000 | 4,360,000 | 7,540,000 |
| 1,700 | 8,000 | 13,600,000 | 4,360,000 | 9,240,000 |

| | | | | |
|---|---|---|---|---|
| 1,700 | 9,000 | 15,300,000 | 4,360,000 | 10,940,000 |
| 1,700 | 10,000 | 17,000,000 | 4,360,000 | 12,640,000 |

- ថ្លៃដើមផលិតកម្ម/១គីឡូក្រាមទាំង៣ឆ្នាំនៅខេត្តព្រៃវែង

| ការចំណាយតាមឆ្នាំ | ចំណាយសរុបតាមឆ្នាំ (រៀល) | ទិន្នផល/ហិកតា (គ.ក) | ថ្លៃដើមដាំដុះ/គ.ក (រៀល) |
|---|---|---|---|
| ថ្លៃដើមឆ្នាំទី១ | 10,380,167 | 1,850 | 5,611 |
| ថ្លៃដើមឆ្នាំទី២ | 6,446,667 | 1,700 | 3,616 |
| ថ្លៃដើមឆ្នាំទី៣ | 6,446,667 | 1,700 | 3,616 |

## ខ. តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំឈូកយកគ្រាប់នៅខេត្តកណ្ដាល(១ហិកតា)

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | ចំណាយសរុប (រៀល) | ចំនួនសាររំលស់ (រៀល) | ការចំណាយក្រោយរំលស់ (រៀល) |
|---|---|---|---|---|---|---|
| **I-ឆ្នាំទី១** | | | | | | |
| **I.ក. ចំណាយ** | | | | **10,936,800** | | **10,163,467** |
| ថ្លៃជួលដី | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ថ្លៃភ្ជួររាស់ដី | ដង | 3 | 150,000 | 450,000 | | 450,000 |
| ពូជឈូក | គុម្ព | 6,667 | 200 | 1,333,400 | | 1,333,400 |
| ឈ្នួលដាំកូនឈូក | គុម្ព | 6,667 | 200 | 1,333,400 | | 1,333,400 |
| កំបោរកសិកម្ម | គ.ក | 100 | 1,200 | 120,000 | | 120,000 |
| ជីគីមីទ្រាប់បាត | គ.ក | 100 | 3,000 | 300,000 | | 300,000 |
| កំប៉ុសគ្រាប់ទ្រាប់បាត | គ.ក | 200 | 2,300 | 460,000 | | 460,000 |
| ឈ្នួលសម្អាតស្មៅ | ដង | 1 | 150,000 | 150,000 | | 150,000 |
| ថ្លៃប្រេងបូមទឹក | ខែ | 6 | 500,000 | 3,000,000 | | 3,000,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |
| ជីគីមីបំប៉ន(Ure, DAP និង Kali)= ៣០០គ.ក/ហិកតា | គ.ក | 300 | 3,000 | 900,000 | | 900,000 |
| ឈ្នួលប្រមូលផលផ្លែឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ម៉ូទ័របាញ់ថ្នាំប្រើខ្សែស្ពាយ | គ្រឿង | 1 | 160,000 | 160,000 | 3 | 53,333 |

| | | | | | | |
|---|---|---|---|---|---|---|
| ម៉ាស៊ីនបូមទឹក | ឈុត | 1 | 1,000,000 | 1,000,000 | 3 | 333,333 |
| **I.ខ.ចំណូល** | | | | **11,800,000** | | **11,800,000** |
| ការលក់គ្រាប់ឈូក | គ.ក | 1,800 | 6,500 | 11,700,000 | | 11,700,000 |
| ផ្សេងៗ( លក់ស្លឹក) | គ.ក | 50 | 2,000 | 100,000 | | 100,000 |
| **I.គ. លទ្ធផលចំណេញ-ខាត = (I.ខ - I.ក)** | | | | **863,200** | | **1,636,533** |
| II-**ឆ្នាំទី២** | | | | | | |
| **II.ក. ចំណាយ** | | | | **6,240,000** | | **6,626,667** |
| ឈ្នួលជួលដី | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ថ្លៃរាស់ដី | ដង | 1 | 150,000 | 150,000 | | 150,000 |
| ជីគីមីបំប៉ន | គ.ក | 100 | 3,000 | 300,000 | | 300,000 |
| ជីធម្មជាតិគ្រាប់បំប៉ន | គ.ក | 200 | 2300 | 460,000 | | 460,000 |
| ថ្លៃប្រេងបូមទឹក | ខែ | 6 | 500,000 | 3,000,000 | | 3,000,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |
| ជីគីមីបំប៉ន(Urea, DAP និង Kali)=៣០០គ.ក/ហិកតា | គ.ក | 300 | 3,000 | 900,000 | | 900,000 |
| ឈ្នួលប្រមូលផលផ្លែឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ម៉ូទ័របាញ់ថ្នាំប្រើខ្សែស្លាយ | គ្រឿង | 1 | 160,000 | 160,000* | 3 | 53,333 |
| ម៉ាស៊ីនបូមទឹក | ឈុត | 1 | 1,000,000 | 1,000,000* | 3 | 333,333 |
| **II.ខ. ចំណូល** | | | | **11,575,000** | | **11,575,000** |
| ការលក់គ្រាប់ឈូក | គ.ក | 1,750 | 6,500 | 11,375,000 | | 11,375,000 |
| ផ្សេងៗ( លក់ស្លឹក) | គ.ក | 100 | 2,000 | 200,000 | | 200,000 |
| **II.គ. លទ្ធផលចំណេញ-ខាតចង្ករត្រឹមឆ្នាំទី២=(II.ខ-II.ក)-I.គ** | | | | **6,198,200** | | **6,584,867** |
| III-**ឆ្នាំទី៣** | | | | | | |
| **III.ក. ចំណាយឆ្នាំទី៣** | | | | **6,240,000** | | **6,626,667** |
| ឈ្នួលជួលដី | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ថ្លៃរាស់ដី | ដង | 1 | 150,000 | 150,000 | | 150,000 |
| ជីគីមីបំប៉ន | គ.ក | 100 | 3,000 | 300,000 | | 300,000 |
| ជីធម្មជាតិគ្រាប់បំប៉ន | គ.ក | 200 | 2300 | 460,000 | | 460,000 |
| ថ្លៃប្រេងបូមទឹក | ខែ | 6 | 500,000 | 3,000,000 | | 3,000,000 |
| ថ្នាំសម្លាប់សត្វល្អិត និងជំងឺ | ដង | 2 | 100,000 | 200,000 | | 200,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ជីគីមីបំប៉ន(Ure, DAP និង Kali)=៣០០គ.ក/ហិកតា | គ.ក | 300 | 3,000 | 900,000 | | 900,000 |
| ឈ្នួលប្រមូលផលផ្លែឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ឈ្នួលប្រឡេះគ្រាប់ឈូក | ដង | 8 | 30,000 | 240,000 | | 240,000 |
| ចំណាយផ្សេង | ឆ្នាំ | 1 | 50,000 | 50,000 | | 50,000 |
| ម៉ូទ័របាញ់ថ្នាំប្រើខ្សែស្ពាយ | គ្រឿង | 1 | 160,000 | 160,000* | 3 | 53,333 |
| ម៉ាស៊ីនបូមទឹក | ឈុត | 1 | 1,000,000 | 1,000,000* | 3 | 333,333 |
| **III.ខ. ចំណូលឆ្នាំទី៣** | | | | **11,675,000** | | **11,675,000** |
| ការលក់គ្រាប់ឈូក | គ.ក | 1,750 | 6,500 | 11,375,000 | | 11,375,000 |
| ចំណូលផ្សេងៗ(លក់ស្លឹក) | គ.ក | 150 | 2,000 | 300,000 | | 300,000 |
| **III.គ. លទ្ធផលចំណេញ/ខាតបង្គរត្រឹមឆ្នាំទី៣= (III.ខ-III.ក)+II.គ** | | | | **11,633,200** | | **11,633,200** |

**សម្គាល់÷** លេខមានសញ្ញាផ្កាយមិនត្រូវបានបូកបញ្ចូលក្នុងការចំណាយឡើយ (ឆ្នាំទី២ និងទី៣)។

### ❖ តារាងសង្ខេបពីចំណេញ/ខាតរយៈពេល៣ឆ្នាំនៅខេត្តកណ្ដាលក្នុងតម្លៃជាមធ្យម៦,៥០០៛/គ.ក

| ឆ្នាំ | ទិន្នផលគ្រាប់ស្ងួត + ស្លឹកសរុប (គ.ក/ហិកតា) | តម្លៃ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | លទ្ធផលបង្គរ ចំណេញ/ខាត (រៀល) |
|---|---|---|---|---|---|
| ទី១ | 1,800 | 6,500 | 11,700,000 | 10,936,800 | 863,200 |
| | 50 | 2,000 | 100,000 | | |
| ទី២ | 1,750 | 6,500 | 11,375,000 | 6,540,000 | 6,198,200 |
| | 100 | 2,000 | 200,000 | | |
| ទី៣ | 1,750 | 6,500 | 11,375,000 | 6,540,000 | 11,633,200 |
| | 150 | 2,000 | 300,000 | | |

### ❖ និន្នាការតម្លៃធៀបនឹងថ្លៃចំណាយទាំង៣ឆ្នាំនៅខេត្តកណ្ដាល

| ទិន្នផលគ្រាប់ស្ងួត/ហ.ត | និន្នាការតម្លៃ (រៀល/គ.ក) | តម្លៃសរុប (រៀល) | ចំណាយឆ្នាំដុល (រៀល) | ចំណេញ/ខាតតាមឆ្នាំ (រៀល) |
|---|---|---|---|---|
| **I-ទិន្នផល និន្នារការតម្លៃ ធៀបនឹងការចំណាយឆ្នាំទី១** | | | | |
| 1,800 | 4,000 | 7,200,000 | 10,936,800 | -3,736,800 |
| 1,800 | 5,000 | 9,000,000 | 10,936,800 | -1,936,800 |
| 1,800 | 5,500 | 9,900,000 | 10,936,800 | -1,036,800 |
| 1,800 | 6,000 | 10,800,000 | 10,936,800 | -136,800 |
| 1,800 | 6,500 | 11,700,000 | 10,936,800 | 763,200 |
| 1,800 | 8,000 | 14,400,000 | 10,936,800 | 3,463,200 |

| | | | | |
|---|---|---|---|---|
| 1,800 | 9,000 | 16,200,000 | 10,936,800 | 5,263,200 |
| 1,800 | 10,000 | 18,000,000 | 10,936,800 | 7,063,200 |
| **II-ទិន្នផល និន្នាការតម្លៃធៀបនឹងការចំណាយឆ្នាំទី២** | | | | |
| 1,800 | 4,500 | 8,100,000 | 6,240,000 | 1,860,000 |
| 1,800 | 5,000 | 9,000,000 | 6,240,000 | 2,760,000 |
| 1,800 | 6,000 | 10,800,000 | 6,240,000 | 4,560,000 |
| 1,800 | 6,500 | 11,700,000 | 6,240,000 | 5,460,000 |
| 1,800 | 8,000 | 14,400,000 | 6,240,000 | 8,160,000 |
| 1,800 | 9,000 | 16,200,000 | 6,240,000 | 9,960,000 |
| 1,800 | 10,000 | 18,000,000 | 6,240,000 | 11,760,000 |
| **III-ទិន្នផល និន្នាការតម្លៃធៀបនឹងការចំណាយឆ្នាំទី៣** | | | | |
| 1,750 | 4,000 | 7,000,000 | 6,240,000 | 760,000 |
| 1,750 | 5,000 | 8,750,000 | 6,240,000 | 2,510,000 |
| 1,750 | 6,000 | 10,500,000 | 6,240,000 | 4,260,000 |
| 1,750 | 6,500 | 11,375,000 | 6,240,000 | 5,135,000 |
| 1,750 | 7,000 | 12,250,000 | 6,240,000 | 6,010,000 |
| 1,750 | 8,000 | 14,000,000 | 6,240,000 | 7,760,000 |
| 1,750 | 9,000 | 15,750,000 | 6,240,000 | 9,510,000 |
| 1,750 | 10,000 | 17,500,000 | 6,240,000 | 11,260,000 |

❖ ថ្លៃដើមផលិតកម្ម/១គីឡូក្រាមទាំង៣ឆ្នាំនៅខេត្តកណ្ដាល

| ការចំណាយតាមឆ្នាំ | ចំណាយសរុបតាមឆ្នាំ (រៀល) | ទិន្នផល/ហិកតា (គ.ក) | ថ្លៃដើមដាំដុះ/គ.ក (រៀល) |
|---|---|---|---|
| ថ្លៃដើមឆ្នាំទី១ | 10,163,467 | 1,800 | 5,646 |
| ថ្លៃដើមទីឆ្នាំ២ | 6,926,667 | 1,750 | 3,787 |
| ថ្លៃដើមឆ្នាំទី៣ | 6,926,667 | 1,750 | 3,787 |

## ៦- ហានិភ័យ បញ្ហាប្រឈម និងដំណោះស្រាយ

ហានិភ័យចំពោះផលិតកម្មដំណាំឈូកដែលកសិករអាចនឹងជួបប្រទះក្នុងកំឡុងពេលដាំដុះដំណាំឈូកយកគ្រាប់÷

| ប្រភេទហានិភ័យ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| | **-ជំងឺផ្សិត-បាក់តេរី÷** ជំងឺរលួយដើម ជំងឺអុច ដែលអាចបំផ្លាញស្លឹក ដើម និងផ្កាឈូក។ | -ការគ្រប់គ្រងជំងឺទាមទារចំណេះដឹង និងការយកចិត្តទុកដាក់ខ្ពស់ជាប្រចាំដោយពិភាក្សាជាមួយអ្នក |

| | | |
|---|---|---|
| **ហានិភ័យផលិតកម្ម** | **-សត្វល្អិត÷** ដង្កូវស៊ីដើម ស្លឹក ផ្លែ សត្វល្អិតបឺតជញ្ជក់ ដែលអាចធ្វើឱ្យខូចខាតដល់ដំណាំ និងកាត់បន្ថយទិន្នផលគ្រាប់ឈូក។ | ជំនាញ។ ជ្រើសរើសពូជឈូកដែលធន់នឹងជំងឺ អាកាសធាតុ និងដីក្នុងតំបន់ដាំដុះ<br>-តាមដាននិងគ្រប់គ្រងសត្វល្អិត÷ប្រើប្រាស់ថ្នាំកសិកម្មដែលមានប្រសិទ្ធភាព និងសុវត្ថិភាព តាមការណែនាំរបស់អ្នកជំនាញ។ |
| | **-គ្រោះរាំងស្ងួត÷** ដំណាំឈូកត្រូវការទឹកជាប្រចាំ ដូច្នេះគ្រោះរាំងស្ងួតអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការលូតលាស់ខ្លាំងបំផុត។<br>**-ទឹកជំនន់÷** ធ្វើឱ្យងាប់ដើម ផ្កា និងផ្លែ មិនអាចប្រមូលផលបាន។<br>**-សីតុណ្ហភាព÷** សីតុណ្ហភាពខ្ពស់ពេកលើស៣៥អង្សារសេ ឬទាបពេកក្រោម ១២ អង្សាសេ ក៏អាចជះឥទ្ធិពលអវិជ្ជមានដល់ការចេញផ្កា និងទិន្នផលផងដែរ។ | **គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រឱ្យបានល្អ÷**<br>-ធានាការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់នៅរដូវប្រាំង (ទីតាំងនៅជិតប្រភពទឹក និងខួងអណ្តូងយកទឹកក្រោមដីមកប្រើប្រាស់)<br>-ត្រូវបង្ហូរ ឬបូមទឹកចេញដោយរក្សាកម្ពស់ទឹកមិនឱ្យលិចដើម និងផ្លែឈូកនៅរដូវវស្សា<br>-រក្សាកម្រិតកម្ពស់ទឹកឱ្យសមស្របដើម្បីឱ្យដំណាំឈូកអាចធន់ទ្រាំនឹងកំដៅ និងលូតលាសបានល្អ។ |
| **ហានិភ័យផលិតកម្ម** | **-គុណភាពទឹក:** ទឹកកខ្វក់ឬទឹកមានជាតិពុលអាចប៉ះពាល់ដល់ការលូតលាស់របស់ដំណាំឈូក។<br>**-គុណភាពដី:** កង្វះសារធាតុចិញ្ចឹមអាចធ្វើឱ្យឈូកលូតលាស់មិនបានល្អ និងងាយរងនឹងកើតជំងឺ។ | - ធ្វើតេស្តគុណភាពទឹកជាប្រចាំ ដើម្បីកែតម្រូវកម្រិត pH ទឹក និងបន្ថែមសារធាតុចិញ្ចឹមចាំបាច់<br>- ចូលរួមវគ្គបណ្តុះបណ្តាលពីមន្ទីរកសិកម្ម ឬអង្គការដៃគូស្តីពីបច្ចេកទេសដាំដុះទំនើប ការកែលម្អគុណភាពដីជាប្រចាំជាពិសេសកម្រិត pH ដី ។ |
| | **បច្ចេកទេសគ្រប់គ្រង**<br>-ការជ្រើសរើសពូជ និងការប្រើប្រាស់ជីច្រើនពេក ឬតិចពេក និងការប្រមូលផលឈូកមិនទាន់គ្រប់អាយុ។ | **អនុវត្តបច្ចេកទេសដាំដុះឱ្យបានត្រឹមត្រូវ÷**<br>-ជ្រើសរើសពូជដែលមានប្រភពច្បាស់លាស់ ការប្រើប្រាស់ជីសរីរាង្គ ឬគីមីតាមកម្រិតសមស្រប និងប្រមូលផលគ្រាប់ផ្លែដែលមានពណ៌ខ្មៅ ឬត្នោតគ្រាប់មានលក្ខណៈរលុង និងពិភាក្សាជាមួយអ្នកមានបទពិសោធន៍អនុវត្តជាក់ស្តែង។ |
| **ហានិភ័យទីផ្សារ** | **-តម្រូវការ:** តម្លៃគ្រាប់ឈូកប្រែប្រួលទៅតាមរដូវកាល ឬតម្រូវការទីផ្សារ។ | **-សិក្សាទីផ្សារឱ្យបានច្បាស់លាស់÷** ស្វែងយល់ពីតម្រូវការផលិតផលឈូក (ផ្កា គ្រាប់ មើម) នៅក្នុងតំបន់ និងទីក្រុង |

| | | |
|---|---|---|
| **ហានិភ័យទីផ្សារ** | **-ការប្រកួតប្រជែង:** ការប្រកួតប្រជែងពីអ្នកដាំដុះផ្សេងទៀតក៏អាចជះឥទ្ធិពលដល់តម្លៃទីផ្សារផងដែរ | **-បង្កើតទំនាក់ទំនងជាមួយអ្នកប្រមូលទិញផ្ទាល់÷** ធានាបាននូវទីផ្សារសម្រាប់ផលិតផលឈូក<br>**-ពិពិធកម្មផលិតផលឈូក÷** កុំពឹងផ្អែកតែលើការលក់គ្រាប់ឈូកមួយមុខដោយពិចារណាលក់ផ្កា មើម ក្រអៅ ឬស្លឹកឈូកដែលសុទ្ធតែមានតម្រូវការ និងការស្តុកទុកគ្រាប់ស្ងួតដោយកុំលក់ពេលដំណាលគ្នាច្រើននាំឱ្យចុះថោក។<br>**-កែច្នៃផលិតផល÷** អាចកែច្នៃគ្រាប់ឈូកជាចំណីអាហារ ម្សៅឈូក គ្រាប់ឈូកលីង ដើម្បីបង្កើនតម្លៃបន្ថែម<br>**-បង្កើតម៉ាកយីហោ និងការវេចខ្ចប់ទាក់ទាញ÷** ដើម្បីបង្កើនតម្លៃ និងភាពទាក់ទាញដល់អ្នកទិញ<br>**-ប្រើប្រាស់បច្ចេកវិទ្យា÷** ផ្សព្វផ្សាយផលិតផលនៅលើបណ្តាញសង្គម ឬវេទិកាអនឡាញដើម្បីពង្រីកទីផ្សារ<br>**-បង្កើតបណ្តុំ ឬសហគមន៍កសិកម្ម÷** រួមគ្នាដើម្បីទទួលបានអំណាចក្នុងការចរចាតម្លៃ និងផែនការទិញ ផលិត លក់ រួមគ្នា។ |
| **ហានិភ័យហិរញ្ញវត្ថុ** | **-ការចំណាយដំបូង÷**ការរៀបចំស្រែឈូក ការទិញពូជ ការដំឡើងប្រព័ន្ធធារាសាស្ត្រអាចទាមទារទុនវិនិយោគដំបូងច្រើន។<br>**-ការចំណាយប្រតិបត្តការ÷** ថ្លៃជីថ្នាំកសិកម្ម ថ្លៃអគ្គិសនី/ប្រេងឥន្ធនៈ ពិសេសថ្លៃកំលាំងពលកម្មពលកម្ម។<br>**-ប្រភពហិរញ្ញវត្ថុ÷** កសិករខ្នាតតូចអាចមានការលំបាកក្នុងការទទួលបានប្រាក់កម្ចីពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុដោយសារតែកង្វះវត្ថុបញ្ចាំ ឬឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។<br>**-ផែនការអាជីវកម្ម÷** កង្វះការធ្វើផែនការអាជីវកម្មដែលច្បាស់លាស់ | **-គ្រប់គ្រងចំណូលចំណាយឱ្យបានល្អ÷** កត់ត្រារាល់ចំណូល និងចំណាយ ដើម្បីដឹងពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដ<br>**-រៀបចំផែនការអាជីវកម្មលម្អិត÷** វាយតម្លៃថ្លៃដើម ប្រាក់ចំណូលដែលរំពឹងទុក និងហានិភ័យ<br>**-ស្វែងរកប្រភពទុន÷**ពិចារណាប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬកម្មវិធីជំនួយរបស់រដ្ឋាភិបាលសម្រាប់វិស័យកសិកម្មដែលមានអត្រាការប្រាក់ទាប។<br>**-ប្រើប្រាស់បច្ចេកទេសកាត់បន្ថយថ្លៃដើម÷** ដូចជាការប្រើប្រាស់ជីធម្មជាតិផលិតដោយខ្លួនឯង ឬប្រព័ន្ធធារាសាស្ត្រសន្សំសំចៃទឹក (ប្រព័ន្ធពន្លឺព្រះអាទិត្យ)។ |

| | | |
|---|---|---|
| | និងការគ្រប់គ្រងចំណូលចំណាយមិនបានត្រឹមត្រូវ អាចនាំឱ្យមានបញ្ហាហិរញ្ញវត្ថុ។ | **-បង្កើតថវិកាបម្រុង÷** សន្សំប្រាក់មួយចំណែកសម្រាប់ទប់ទល់នឹងហានិភ័យដែលកើតឡើងដោយចៃដន្យ។<br>**-ស្វែងយល់ពីកម្មវិធីធានារ៉ាប់រងដំណាំ** (បើមាន) ដើម្បីកាត់បន្ថយហានិភ័យនៃការខាតបង់ធំ។ |

## ៧-សេចក្តីសន្និដ្ឋាន

ដំណាំឈូកយកគ្រាប់មានលក្ខណៈពិសេសមួយចំនួនដូចជា÷ ផ្តល់ផលលឿន ត្រឹមអាយុជាមធ្យមពីខែទី៤-៥ឡើងទៅ អាចផ្តល់ផលគ្រាប់ទុំស្ងួតជាមធ្យម ១,៥០០-២,០០០គ.ក/ហិកតា/ឆ្នាំ និងមានកូនដុះបន្តមិនបាច់ដាំកូនថ្មីទៀតរហូតដល់៣-៥ឆ្នាំ មានទីផ្សារក្នុងស្រុកល្អ និងអាចមានឱកាសនាំចេញនៅថ្ងៃអនាគត។

តាមរយៈតារាងនៃការវិភាគសេដ្ឋកិច្ចបង្ហាញថា ដំណាំឈូកយកគ្រាប់អាចទទួលផលចំណេញចាប់ពីឆ្នាំទី២ ហើយអាចបន្តចំណេញដល់ឆ្នាំទី៣ ឬលើសពីនេះបើមានការថែទាំបានល្អ។ ចំណែកតម្លៃជាមធ្យម ៦,០០០រៀល ទៅ ៦,៥០០រៀល/គ.ក (តម្លៃក្នុងកំឡុងពេលសិក្សានេះ) សម្រាប់ទីផ្សារក្នុងស្រុកដែលកសិករអាចទទួលផលចំណេញបាន។ សម្រាប់ថ្លៃដើមផលិតនៅឆ្នាំទី១ចន្លោះ ៥,៦១១រៀល-៥,៦៤៦រៀល/គីឡូក្រាម និងចាប់ពីឆ្នាំទី២ឡើងទៅចន្លោះ ៣,៦១៦-៣,៧៨៧រៀល/គីឡូក្រាម។ ចំពោះនិន្នាការតម្លៃគ្រាប់ឈូកស្ងួត ជាទូទៅអាចប្រែប្រួលចន្លោះពី ៤,០០០រៀល- ១០,០០០រៀល អាស្រ័យលើបរិមាណនៃការផ្គត់ផ្គង់ គុណភាពគ្រាប់ឈូកនិងភាគរយសំណើមចុងក្រោយរបស់គ្រាប់។

## ៨-ប្រភពឯកសារ÷


១- សិក្សាផ្ទាល់លើការអនុវត្តជាក់ស្តែងរបស់កសិករដាំដុះដំណាំឈូកនៅខេត្តព្រៃវែង

២- សិក្សាផ្ទាល់លើការអនុវត្តជាក់ស្តែងរបស់កសិករដាំដុះដំណាំឈូកនៅខេត្តកណ្តាល

៣- Zhou P, Jin Q, Qian P, Wang Y, Wang X, et al. 2022. *Genetic resources of lotus (Nelumbo) and their improvement.* Ornamental Plant Research 2:5 https://doi.org/10.48130/OPR-2022-0005

៤- Zhang X, Wang Q. 1966. *Preliminary observation on the morphological and biological characteristics of lotus varieties.* Acta Horticulture Sinica 2:89−102

៥- Zhang X, Wang Q. 2006. *Preliminary study of the eco-types of genetic resources of tropical Lotus.* Chin Landscape Arch 7:82−85

៦- Huang W, Wang P, Huang CF, Li H. 2010. *Advance in research on antibacterial activity of extract in lotus leaf.* Nonwood Forest Research 28:137−41

៧- Wang Q, Zhang X, Bao M. 2004. *Lotus flower cultivars in China. Beijing*: China Forestry Publishing House

៨- Burlakova LE, Karatayev AY. 2007. *The effect of invasive macrophytes and water level fluctuations on unionids in Texas impoundments.* Hydrobiology 586:291−302

៩- Hu J, Pan L, Liu H, Wang S, Wu Z, et al. 2012. *Comparative analysis of genetic diversity in sacred lotus (Nelumbo nucifera Gaertn.) using AFLP and SSR markers.* Molecular Biology Reports 39:3637−47